00278451

C26/5/13

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

**សំណុំរឿងព្រហ្មទណ្ឌ លេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ១៥)**

**ចំពោះមុខ:** ចៅក្រម ប្រាក់ គឹមសាន ~~ប្រធាន~~
ចៅក្រម Rowan DOWNING
ចៅក្រម នៃយ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

**កាលបរិច្ឆេទ:** ៦ កុម្ភៈ ២០០៩

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 06 / FEB / 2009
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CA.Any

---

**សាធារណៈ:**

# សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា ដើម្បីកំណត់លើបណ្តឹងឧទ្ធរណ៍ដោយផ្អែកលើមូលដ្ឋាននៃសារណាជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ និងដីកាកំណត់កាលបរិច្ឆេទសវនាការ

---

**ការិយាល័យសហព្រះរាជអាជ្ញា**

ជា លាង
Robert PETIT
យ៉ែត ចរិយា
William SMITH
ពេជ្រ សម្បត្តិ
Vincent de WILDE d'ESTMAEL

**ជនត្រូវចោទ**

ខៀវ សំផន

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ហុង គឹមសួន
ឡោ ជុនធី
នី ចាន់ឌី
គង់ ពិសី
យុង ផានិត
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUZINSKY
Martine JACQUIN
Philippe CANNONE
Pierre Olivier SUR

**សហមេធាវីការពារក្តី**

ស ស្វាន
Jacques VERGÉS

00278452



១. **អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") កត់សម្គាល់ឃើញមាន "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ **ខៀវ សំផន** ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន" ("ចម្លើយតប")។ ចម្លើយតបនេះ បានដាក់នៅថ្ងៃទី៩ ខែមករា ឆ្នាំ២០០៩ ដែលនៅក្នុងនោះ សហព្រះរាជអាជ្ញាស្នើសុំឱ្យអង្គបុរេជំនុំជម្រះ សម្រេចលើបណ្តឹងឧទ្ធរណ៍ ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ ("សំណើ")។

២. នៅក្នុងសំណើរបស់ខ្លួន, សហព្រះរាជអាជ្ញាសន្និដ្ឋានថា "ទោះបីសហព្រះរាជអាជ្ញាគាំទ្រសវនាការផ្ទាល់មាត់សម្រាប់បណ្តឹងឧទ្ធរណ៍ក៏ដោយ ក៏ប៉ុន្តែបណ្តឹងឧទ្ធរណ៍មួយនេះទាក់ទងតែទៅនឹងការបន្តថិរវេលានៃការឃុំខ្លួន ហើយបណ្តឹងឧទ្ធរណ៍នេះ ពុំបានលើកអំណះអំណាងអង្គហេតុ ឬ អង្គច្បាប់ថ្មីៗដែលចាំបាច់សម្រាប់សវនាការផ្ទាល់មាត់ទេ។"[១]

៣. នៅក្នុងសេចក្តីបង្គាប់ចេញថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩, អង្គបុរេជំនុំជម្រះបានអញ្ជើញឱ្យភាគីនានា ដែលពាក់ព័ន្ធនៅក្នុងរឿងក្តីនេះ ដាក់សេចក្តីសន្និដ្ឋានតប ត្រឹមថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៩។

៤. នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៩, សហមេធាវីការពារក្តីបានដាក់ចម្លើយតបរបស់ខ្លួនទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា។ នៅក្នុងសេចក្តីសន្និដ្ឋានតបនោះ សហមេធាវីការពារក្តីស្នើសុំឱ្យអង្គបុរេជំនុំជម្រះបើកសវនាការជាសាធារណៈលើបណ្តឹងឧទ្ធរណ៍នេះ ដោយសារបណ្តឹងឧទ្ធរណ៍នេះលើកឡើងបញ្ហាគតិយុត្តថ្មី ហើយពាក់ព័ន្ធនឹងសិទ្ធិជាមូលដ្ឋានរបស់ជនត្រូវចោទក្នុងការទទួលបាននូវសេរីភាព។[២] សហមេធាវីការពារក្តីស្នើសុំបន្ថែមទៀតថា "សារណាបណ្តឹងឧទ្ធរណ៍របស់ខ្លួនចំពោះដីកាបដិសេធការដោះលែងឱ្យមានសេរីភាព ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨" ដែលបានដាក់នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៨ គួរយកមកជំនុំជម្រះនៅក្នុងពេលសវនាការជាមួយគ្នាតែម្តង ដោយសារបណ្តឹងឧទ្ធរណ៍ទាំងពីរនេះពាក់ព័ន្ធនឹងអនីត្យានុកូលភាពនៃការឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្ន។ ដូច្នេះ បណ្តឹងឧទ្ធរណ៍ទាំងពីរនេះ មានការពាក់ព័ន្ធគ្នា។

---

[១] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ **ខៀវ សំផន** ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ននៃថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨, ចុះថ្ងៃទី៩ ខែមករា ឆ្នាំ២០០៩ C26/5/10 វាក្យខណ្ឌទី ៤។

[២] ចម្លើយតបរបស់ក្រុមការពារក្តីទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យសម្រេចលើសារណាជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៩ C26/5/12 វាក្យខណ្ឌទី ២។

៥. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សហព្រះរាជអាជ្ញាក៏បានស្នើសុំឱ្យសម្រេចបណ្ដឹងឧទ្ធរណ៍ចំពោះដីកាបដិសេធការដោះលែងឱ្យមានសេរីភាព ដោយផ្អែកលើសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះដែរ។[៣]

៦. វិធាន ៧៧ នៃវិធានផ្ទៃក្នុង (វ.២) ចែងនៅក្នុងវិធានច្បាប់ដែលពាក់ព័ន្ធថា:

> "៣. (ខ) បន្ទាប់ពីបានពិចារណាលើការយល់ឃើញរបស់ភាគី អង្គបុរេជំនុំជម្រះអាចសម្រេចលើបណ្ដឹងឧទ្ធរណ៍ ឬពាក្យសុំ ដោយផ្អែកតែលើមូលដ្ឋាននៃសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ភាគីតែប៉ុណ្ណោះ។"

៧. ដោយទទួលស្គាល់អំពីសារៈសំខាន់នៃបណ្ដឹងឧទ្ធរណ៍ទាំងពីរ ដែលពាក់ព័ន្ធនឹងសេរីភាពរបស់ជនត្រូវចោទ និងដោយពិចារណាថា ក្រុមមេធាវីការពារក្ដី បានស្នើសុំឱ្យមានសវនាការដេញដោល, អង្គបុរេជំនុំជម្រះយល់ឃើញថា វាជាការសមស្របក្នុងការរៀបចំសវនាការនេះឡើង មុនពេលសម្រេចលើបណ្ដឹងឧទ្ធរណ៍ទាំងនេះ។

៨. ដោយពិចារណាឃើញថា បណ្ដឹងឧទ្ធរណ៍ប្រឆាំងចំពោះដីកាបដិសេធការដោះលែងឱ្យមានសេរីភាព នឹងរៀបចំរួចរាល់សម្រាប់ការជំនុំជម្រះក្នុងពេលឆាប់ៗនេះ ហើយបណ្ដឹងឧទ្ធរណ៍នេះ បានលើកឡើងបញ្ហានានា ដែលជាប់ទាក់ទងជិតស្និទទៅនឹងបណ្ដឹងឧទ្ធរណ៍ប្រឆាំងចំពោះដីកាសម្រេចអំពីការបន្តចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន, អង្គបុរេជំនុំជម្រះនឹងបើកសវនាការលើបណ្ដឹងឧទ្ធរណ៍ទាំងពីរនេះ រួមគ្នាតែម្ដង។

៩. សវនាការលើរឿងក្ដីទាំងនេះ ត្រូវធ្វើឡើងជាសាធារណៈ។

---

[៣] សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ១៤), ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសារណាបណ្ដឹងឧទ្ធរណ៍របស់ជនត្រូវចោទ ខៀវ សំផន ប្រឆាំងនឹងដីកាបដិសេធការដោះលែងឱ្យមានសេរីភាពនៃថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨, ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៩ C40/5/2 វាក្យខណ្ឌទី ៦។



E.C.C.C. * C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

00278454



**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះ÷**

(១) **បដិសេធចោល**សំណើសុំឱ្យធ្វើការសម្រេចលើបណ្តឹងឧទ្ធរណ៍ ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរណ៍តែប៉ុណ្ណោះ នៅក្នុងសំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ១៤) និង ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ១៥)។

(២) **កំណត់**បើកសវនាការលើបណ្តឹងឧទ្ធរណ៍ប្រឆាំងចំពោះដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន និងបណ្តឹងឧទ្ធរណ៍ប្រឆាំងចំពោះដីកាបដិសេធការដោះលែងឱ្យមានសេរីភាព **នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៩ វេលាម៉ោង ៩:០០ ព្រឹក**។ និង

(៣) **អញ្ជើញ**គ្រប់ភាគីដែលពាក់ព័ន្ធនឹងរឿងក្តីនេះ ចូលរួមនៅក្នុងសវនាការតាមកាលបរិច្ឆេទកំណត់។ /ៗ/

ភ្នំពេញ ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០០៩

**ប្រធានអង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន**